# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀងស្នើសុំព្យួរកិច្ចសន្យាការងារ

ដោយសារតែក្រុមហ៊ុនយើងខ្ញុំខ្វះវត្ថុធាតុដើមអំឡុងពេលបច្ចុប្បន្ន ដូចនេះនាយកក្រុមហ៊ុន **ហាតអ៊ីនធើប្រាយ (ខេមបូឌា) ខូអិលធីឌី** និងកម្មករនិយោជិតទាំងអស់បានព្រមព្រៀងគ្នា ព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ២០៤នាក់ (ស្រី ១៦៨ នាក់) ក្នុងចំណោមកម្មករសរុប ៤៦១នាក់ (ស្រី ៣៨៩) រយៈពេល ៦១ថ្ងៃ ដោយគិតចាប់ពី **ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០២៣** រហូតដល់**ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៣។** ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន **៦០ដុល្លារ (ហុកសិបដុល្លារអាមេរិកគត់)** សម្រាប់ការផ្តល់ជូនប្រាក់ឧបត្ថមមានដូចខាងក្រោម៖

- ចំនួន៣០ដុល្លារ ផ្តល់ជូនសម្រាប់ព្យួរកិច្ចសន្យាការងារចាប់ពី**ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣** ដល់**ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣** សម្រាប់ប្រាក់ឧបត្ថម្ភក្រុមហ៊ុននឹងបើកជូននៅ**ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣** តាមរយៈធនាគាររីង។
- ចំនួន៣០ដុល្លារ ផ្តល់ជូនសម្រាប់ព្យួរកិច្ចសន្យាការងារចាប់ពី**ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៣** ដល់**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** សម្រាប់ប្រាក់ឧបត្ថម្ភក្រុមហ៊ុននឹងបើកជូននៅ**ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣** តាមរយៈធនាគាររីង។

អង្គប្រជុំបានចប់នៅវេលាម៉ោង០៨នឹង៣០នាទី ព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ នឹងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

ដើម្បីជាភស្តុតាងលើលិខិតស្នើសុំព្យួរកិច្ចសន្យាការងារនេះ យើងខ្ញុំទាំងអស់គ្នា សូមផ្តិតមេដៃដូចខាងក្រោមនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០២៣

តំណាងកម្មករនិយោជិត

ហត្ថលេខា និងត្រានាយកក្រុមហ៊ុន